**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ៤១៦៦ អពដ

ថ្ងៃ អង្គារ ១១ កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលប្រកាសបង់ប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធសម្រាប់ឆ្នាំ ២០១៨

អនុលោមតាមប្រកាសលេខ ៩៨២ សហវ.ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រ៊ីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន លោក/លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬម្ចាស់អាជីវកម្មដ្ឋានទាំងអស់ ដែលបានលើកស្លាកអាជីវកម្មដ្ឋាន ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម និងផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម មេត្តាជ្រាបថា ការប្រមូលពន្ធតែមប្រ៊ីសារពើពន្ធត្រូវបានបញ្ចប់ត្រឹមថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា មកដល់ពេលនេះមានម្ចាស់សហគ្រាស និងម្ចាស់អាជីវកម្មដ្ឋានជាច្រើនបានមកប្រកាសបង់ពន្ធតែមប្រ៊ីសារពើពន្ធសម្រាប់ឆ្នាំ២០១៨ ហើយក៏នៅមានម្ចាស់សហគ្រាសនិងម្ចាស់អាជីវកម្មដ្ឋានមួយចំនួនទៀត នៅមិនទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធតែមប្រ៊ីសារពើពន្ធនៅឡើយ។ ដើម្បីផ្តល់លទ្ធភាពជូនម្ចាស់សហគ្រាស និងម្ចាស់អាជីវកម្មដ្ឋាន ដែលមិនទាន់បានមកប្រកាសបង់ពន្ធតែមប្រ៊ីសារពើពន្ធ មានពេលវេលាគ្រប់គ្រាន់ក្នុងការមកប្រកាសបង់ពន្ធ អគ្គនាយកដ្ឋានពន្ធដារ សម្រេចពន្យារពេលការប្រកាសបង់ពន្ធតែមប្រ៊ីសារពើពន្ធសម្រាប់ឆ្នាំ២០១៨រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

ចំពោះសហគ្រាស ឬអាជីវកម្មដ្ឋានស្ថិតនៅក្នុងរាជធានីភ្នំពេញ ត្រូវមកដាក់លិខិតប្រកាសបង់ប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធនៅទីចាត់ការពន្ធដាររាជធានីភ្នំពេញ ដែលមានអាសយដ្ឋាននៅអាគារលេខ ៩២F (ក្បែរអគ្គនាយកដ្ឋានពន្ធដារ) មហាវិថីសហព័ន្ធរុស្ស៊ី (១១០) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដោយឡែក សហគ្រាស ឬអាជីវកម្មដ្ឋាន ដែលស្ថិតនៅតាមបណ្តាខេត្ត ត្រូវមកដាក់លិខិតប្រកាសបង់ប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធនៅតាមបណ្តាសាខាពន្ធដារខេត្ត នីមួយៗ។ ម្ចាស់សហគ្រាសនិងម្ចាស់អាជីវកម្មដ្ឋាន ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតលើកស្លាកសញ្ញាអាជីវកម្មពីអាជ្ញាធរ ឬស្ថាប័នពាក់ព័ន្ធ រូបថតនិងទំហំស្លាក បង្កាន់ដៃប្រាក់ពន្ធបានបង់ឆ្នាំមុន ប័ណ្ណពន្ធប៉ាតង់ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

លោក/លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬម្ចាស់អាជីវកម្មដ្ឋាន អាចទាញយកទម្រង់លិខិតប្រកាសពន្ធតែមប្រ៊ីសារពើពន្ធ តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ (www.tax.gov.kh) ឬទទួលយកនៅទីចាត់ការពន្ធដាររាជធានីភ្នំពេញ ឬសាខាពន្ធដារខេត្ត។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ការពន្យារកាលបរិច្ឆេទខាងលើនេះ នឹងជួយសម្រួលដល់លោក/លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬម្ចាស់អាជីវកម្មដ្ឋាន ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។ ក្នុងករណីហួសកាលកំណត់នេះ សហគ្រាស ឬអាជីវកម្មដ្ឋានរបស់លោក/លោកស្រីត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។

Collection by VCAT Professional Consultant

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**